

# 4 តើអ្នកបានបំពេញព័ត៌មានបួន ជំនាន់ នៅក្នុងមែកធាងរបស់អ្នកហើយឬនៅ ?

*ពួកយើងទាំងអស់គ្នាមានជីដូនជីតាដែលបានចែកឋានទៅឯម្ខាងទៀតនៃវាំងនន ដែលកំពុងរង់ចាំយ៉ាងអន្ទះសារដើម្បីទទួលពិធីបរិសុទ្ធនានាក្នុងព្រះវិហារបរិសុទ្ធ ។ ពួកយើងទាំងអស់គ្នាអាចធ្វើជាអ្នកប្រមូលផ្តុំក្រុមគ្រួសាររបស់យើងទាំងសង្ខាងនៃវាំងនន ។ នៅពេលយើងផ្តោតយកចិត្តទុកដាក់ទៅលើកិច្ចការព្រះវិហារបរិសុទ្ធ និងពង្សប្រវត្តិយ៉ាងសកម្ម នោះយើងនឹងទទួលអារម្មណ៍ពីព្រះវិញ្ញាណ ហើយនឹងជួយពង្រឹងដល់ក្រុមគ្រួសាររបស់យើង និងជំនឿរបស់យើងទៅលើព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ ។*

- និយាយទៅកាន់ជីដូនជីតាដែលនៅរស់របស់អ្នក
- បំពេញកូនសៀវភៅបួនជំនាន់នៅលើ *ពង្សប្រវត្តិ: ចាប់ផ្តើមឥឡូវនេះ*
- បន្ថែមឈ្មោះទៅក្នុង familysearch.org/myfamily ឬ lite.fs.org
- នាំយកឈ្មោះគ្រួសាររបស់អ្នកទៅព្រះវិហារបរិសុទ្ធដើម្បីទទួលបានពិធីបរិសុទ្ធនានា

familysearch.org/myfamily

lite.fs.org

**គណៈប្រធានតំបន់អាស៊ី**

ពួកយើងសូមអញ្ជើញសមាជិករបស់យើងនៅក្នុងប្រទេសកម្ពុជា ប្រទេសឥណ្ឌា ប្រទេសឥណ្ឌូណេស៊ី ប្រទេសម៉ុងហ្គោលី និងប្រទេសថៃឲ្យធ្វើការខិតខំរួមគ្នាដើម្បីនិយាយទៅកាន់សមាជិកគ្រួសារដែលនៅរស់របស់ពួកគេដើម្បីដឹងពីជីដូនជីតារបស់ពួកគេ បំពេញព័ត៌មានមនុស្សទាំងបួនជំនាន់នៅលើមែកធាងគ្រួសាររបស់ពួកគេ ហើយបើអាចធ្វើទៅបានសូមនាំឈ្មោះគ្រួសាររបស់ពួកគេផ្ទាល់នោះទៅកាន់ព្រះវិហារបរិសុទ្ធ ។ ■